**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តបាត់ដំបង**
សំណុំរឿងរដ្ឋប្បវេណីលេខ ១៣៩
ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២
សាលក្រមរដ្ឋប្បវេណីលេខ ១០៦ "ឌ"
ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តបាត់ដំបង

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការជាសាធារណៈ នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ លើសំណុំរឿងរដ្ឋប្បវេណីលេខ ១៣៩ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ដោយមានសមាសភាពៈ

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តបាត់ដំបង

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តបាត់ដំបង

ដើមចោទឈ្មោះ [redacted] ទូច ភេទស្រី អាយុ៤៦ ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ [redacted] មានទីលំនៅបច្ចុប្បន្ន [redacted] ។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ។

ចុងចម្លើយឈ្មោះ [redacted] សំអឿន ភេទប្រុស អាយុ៥២ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted]។

## អង្គហេតុ និង ចំណុចវិវាទ

១/ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ

១/១.សុំបញ្ជាក់នត្ថិភាពអាពាហ៍ពិពាហ៍ពីចុងចម្លើយឈ្មោះ [redacted] សំអឿន តាមផ្លូវច្បាប់។

១/២.សុំឲ្យចុងចម្លើយចុះចេញពីលំនៅដ្ឋាន ។

១/៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

២/ អង្គហេតុដែលជាមូលហេតុនៃការទាមទារ

ដើមចោទបានរួមរស់នៅ ជាមួយនឹងចុងចម្លើយតាមប្រពៃណី ក្នុងអំឡុងខែមីនា ឆ្នាំ២០១៧ ដោយពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ឡើយ ។ ក្នុងអំឡុងពេលរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធពុំមានកូនទេ។ ដោយឡែកចំពោះទ្រព្យរួម និងបំណុលគ្មានទេ។ ក្នុងការរួមរស់នៅជាមួយគ្នានេះទៀតសោត ឃើញថាមិនចុះសម្រុងនឹងគ្នា តែងតែមានការឈ្លោះប្រកែកគ្នា មិនទុកចិត្តគ្នា ហាក់បីដូចមិនមែនជាប្តីប្រពន្ធនឹងគ្នា មិនតែប៉ុណ្ណោះឈ្មោះ [redacted] សំអឿន ធ្លាប់ចុះចោលផ្ទះ ហើយលួចទៅទាក់ទងជាមួយស្រីផ្សេង ហើយថែមទាំងគំរាមគំហែង បំផ្លាញទ្រព្យសម្បត្តិ និងរករឿងប្រើហិង្សាមកលើដើមចោទទៀតផង បណ្តាលឱ្យការរួមរស់នៅជាមួយគ្នារវាងរបស់ដើមចោទ និង ចុងចម្លើយមិនអាចបន្តទៅមុខទៀតបាន ដែលជាហេតុនាំឱ្យដើមចោទដាក់ពាក្យប

ណ្តឹងមកតុលាការ ។ ដូច្នេះហើយ ទើបដើមចោទសូមឱ្យតុលាការជួយចេញសាលក្រម បញ្ជាក់នត្តិភាពចំណងអាពាហ៍ពិពាហ៍ និងសុំឲ្យចុងចម្លើយចុះចេញពីលំនៅដ្ឋាន ។

៣/<u>អំពីចំណុចវិវាទ៖</u> តើចុងចម្លើយពិតជាមានសិទ្ធិរស់នៅលើដី និងផ្ទះជាលំនៅដ្ឋានរបស់ដើមចោទដែរឬទេ?

៤/<u>អំពីភស្តុតាង</u>៖ (គ្មាន)

៥/ <u>ការអះអាងរបស់គូភាគីក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល</u>

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] ទូច ធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនតំណាងដោយអាណត្តិឲ្យដើមចោទ សុំថ្លែងការណ៍អំពីអង្គហេតុដូចក្នុងពាក្យបណ្តឹង និង ទាមទារដូចពាក្យបណ្តឹងនៅដដែល ។

ចុងចម្លើយឈ្មោះ [redacted] សំអឿន ធ្វើសេចក្តីថ្លែងការណ៍ថា: ខ្លួនបានរួមរស់នៅជាមួយដើមចោទក្នុងអំឡុងខែ មីនា ឆ្នាំ ២០១៧ ដោយការរស់នៅជាមួយភាគីដើមចោទ ខ្លួន និង ដើមចោទពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍នឹងគ្នាស្របច្បាប់ទេ ។ នៅក្នុងអំឡុងពេលដែលខ្លួន និង ដើមចោទរស់នៅជាមួយគ្នា ពុំមានកូនទេ ប៉ុន្តែមានទ្រព្យរួមចំនួន ពីរ គឺដី និង ឡាន ប៉ុន្តែដើមចោទដាក់ឈ្មោះគាត់ជាម្ចាស់កម្មសិទ្ធិ។ ដី ០១ កន្លែង ដែលខ្លួនអះអាងថាជាទ្រព្យរួមនោះ គឺកើតក្រោយការរួមរស់នៅជាមួយគ្នា ប៉ុន្តែខ្លួនពុំមានភស្តុតាងជាឯកសារ បញ្ជាក់ថាជាទ្រព្យរួមទេ ប៉ុន្តែ មានមេភូមិដែលជាអាជ្ញាធរ ដឹងលឺ និង កាលបរិច្ឆេទ នៃការទិញដីនោះ ។ ហើយចំពោះឡាន ក៏ដើមចោទដាក់ឈ្មោះ គាត់ជាម្ចាស់កម្មសិទ្ធិផងដែរ ។ ចំពោះការទាមទាររបស់ចោទ ដែលសុំឲ្យខ្លួនឲ្យចាកចេញពីផ្ទះ នោះលុះត្រា តែភាគីដើមចោទ ប្រគល់ប្រាក់មកឲ្យខ្លួនមានដើមទុនទៅរកស៊ីខ្លះ ។

ដើមចោទឈ្មោះ [redacted] ទូច ថ្លែងការណ៍តបថា: ខ្លួនសុំបញ្ជាក់ថា ចំពោះទ្រព្យរួមដែលចុងចម្លើយលើកឡើង នោះគឺខ្លួនសុំបដិសេធ ព្រោះជាទ្រព្យដោយឡែកដែលខ្លួនយកប្រាក់ខ្លួនទៅទិញដោយផ្ទាល់ ។ នៅក្នុងការរួមរស់នៅជាមួយគ្នានោះ គឺខ្លួនត្រូវបង់ថ្លៃចិញ្ចឹមកូនចុងចម្លើយ ក្នុង ០១ ខែពី១ ម៉ឺនទៅ ២ ឬ ៣ ម៉ឺនបាត រហូតមក នេះគឺជាបន្ទុករបស់ខ្លួនដែលត្រូវបង់ទៅចុងចម្លើយ ដើម្បីឲ្យគាត់ទៅចិញ្ចឹមកូនគាត់ ។ ចំពោះការទិញឡាន ក៏ខ្លួនបានទិញដោយប្រើលុយផ្ទាល់ខ្លួន ពុំមែនជាលុយរបស់ចុងចម្លើយទេ ។ ចំពោះការដែលចុងចម្លើយសុំឲ្យខ្លួនប្រគល់លុយឲ្យចុងចម្លើយដើម្បីឲ្យគាត់បានយកទៅរកស៊ី នោះគឺខ្លួនអាចឲ្យខ្លះ គឺចំនួន ១០០០ $ (មួយពាន់ដុល្លារអាមេរិក) ក្រៅពីនេះមាស ចំនួន ៧,៥ តម្លឹង និង ផ្លាកទីនប្រហែលជាង ៤ តម្លឹង ដែលខ្លួនបានទិញឲ្យទៅភាគីចុងចម្លើយពីមុននោះគឺ ខ្លួនប្រគល់ឲ្យទៅចុងចម្លើយទាំងអស់ ។

ចុងចម្លើយឈ្មោះ [redacted] សំអឿន ថ្លែងការណ៍តបថា:ខ្លួនមិនឯកភាពក្នុងការទទួលយកប្រាក់ចំនួន ១០០០ $ ពីដើមចោទ នោះទេគឺខ្លួនសុំទាមទារចំនួន ២០.០០០$ (ពីរម៉ឺនដុល្លារអាមេរិក) ពីដើមចោទ ដើម្បីជាថ្នូរនឹងការចាកចេញពីផ្ទះនេះ ។ ខ្លួនសុំបញ្ជាក់ថាមាស ចំនួន ៧,៥ តម្លឹង និង ផ្លាកទីនប្រហែលជាង ៤ តម្លឹង គឺពិតជានៅហ្នឹងខ្លួនរបស់ខ្លួនពិតមែន ។

ដើមចោទឈ្មោះ [redacted] ទូច ថ្លែងការណ៍តបថា: ខ្លួនសុំជំទាស់លើការស្នើសុំរបស់ភាគីចុងចម្លើយដែលទាមទារពីខ្លួនចំនួន ២០.០០០ $ (ពីរម៉ឺនដុល្លារអាមេរិក)ជាថ្នូរនឹងការចាកចេញពីផ្ទះរបស់ខ្លួននោះ ព្រោះខ្លួនពុំមានលទ្ធភាពប្រគល់ប្រាក់នេះឲ្យចុងចម្លើយទេ ដោយសារសព្វថ្ងៃខ្លួនកំពុងតែជំពាក់បំណុលគេ ចំនួន ២០ ម៉ឺនបាត ។

៦/ ការអះអាងរបស់គូភាគីក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] ទូច ធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនតំណាងដោយអាណត្តិឲ្យដើមចោទ សុំថ្លែងការណ៍ទាមទារដូចក្នុងសេចក្តីថ្លែងការណ៍នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០២២ នៅដដែល ។

ភាគីចុងចម្លើយឈ្មោះ [redacted] សំអឿន ថ្លែងការណ៍តបថា ៖ ខ្លួនមិនព្រមបញ្ជាក់អំពីនត្ថិភាពនៃអាពាហ៍ពិពាហ៍នេះទេ ព្រោះខ្លួនរស់នៅជាមួយភាគីដើមចោទ ជាប្តីប្រពន្ធធម្មតា ។ ប៉ុន្តែបើក្នុងករណីដែលភាគីដើមចោទនៅតែរក្សាការទាមទារដូចក្នុងពាក្យបណ្តឹងដដែល នោះគឺ ខ្លួនមានសំណូមពរចំនួន ២ ចំណុច:ទី១ សុំឲ្យដើមចោទប្រគល់ប្រាក់ចំនួន ២៣ ម៉ឺនបាត ដែលដើមចោទយកខ្សែករ ខ្លួនយកទៅលក់ កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០២១ និង ស្នើសុំដើមចោទលះបង់ការទាមទារលុយចំនួន ៧៥០០ $ ជាប្រាក់ដែលខ្លួនបានខ្ចីពីដើមចោទចាប់ពីពេលនេះតទៅ ។ចំពោះការទាមទាររបស់ខ្លួនក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលខ្លួនបានទាមទារពីដើមចោទ ចំនួន ២០០០០ $ នោះគឺខ្លួនមិនទាមទារដល់ចំណុចនេះទៀតទេ គឺមានតែមានសំណូមពរពីរចំណុចនេះទេ ដើម្បីជាថ្នូរនឹងការទាមទាររបស់ចោទខាងលើ ។

ភាគីដើមចោទឈ្មោះ [redacted] ទូច ថ្លែងការណ៍តបថា: ខ្លួនយល់ព្រមតាមសំណូមពររបស់ចុងចម្លើយថ្លែងការណ៍ខាងលើ គឺព្រមប្រគល់ប្រាក់ចំនួន ២៣ ម៉ឺនបាត ឲ្យទៅចុងចម្លើយ និង សុខចិត្តលះបង់ការទាមទារប្រាក់ចំនួន ៧.៥០០$ ដែលចុងចម្លើយបានខ្ចីខ្លួន ហើយក៏សុំបញ្ចប់គ្នាថ្ងៃនេះតែម្តងដោយសុំមិនឲ្យចុងចម្លើយរួមរស់នៅលើដី និង ផ្ទះជាលំនៅដ្ឋានរបស់ខ្លួនចាប់ពីពេលនេះតទៅ ។

លោកមេធាវី [redacted] ថ្លែងការណ៍ថា: ខ្លួនមិនមានអ្វីបន្ថែមទេ គឺខ្លួនឯកភាពតាមការថ្លែងការណ៍របស់កូនក្តីខ្លួន ។

## សំអាងហេតុ

*ឆ្លងតាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖*

១/ ស្តីអំពីការបញ្ជាក់នត្ថិភាពអាពាហ៍ពិពាហ៍

តាមការអះអាងរបស់ភាគីដើមចោទឈ្មោះ [redacted] ទូច និងចុងចម្លើយឈ្មោះ [redacted] សំអឿន អាចឱ្យតុលាការជឿជាក់បានថាដើមចោទ និងចុងចម្លើយពិតជាបានរួមរស់ជាមួយគ្នាមានលក្ខណៈជាប្តីប្រពន្ធ ហើយពិតជាមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទៅតាមផ្លូវច្បាប់ពិតមែន ។ ការដែលដើមចោទ និងចុងចម្លើយ មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍បែបនេះមានន័យថាដើមចោទ និងចុងចម្លើយមិនមានជាប់ចំណងអាពាហ៍ពិពាហ៍នោះទេ គឺរស់នៅជាមួយគ្នាជាលក្ខណៈអនីតិសង្វាសតែប៉ុណ្ណោះ ។ ហេតុនេះការរស់នៅជាមួយគ្នាកន្លងមករបស់គូភាគី គឺជាការរួមរស់លក្ខណៈអនីតិសង្វាស់ គូភាគីមានសិទ្ធិរៀបអាពាហ៍ពិពាហ៍រៀងៗខ្លួន ដោយគូភាគីគ្មានសិទ្ធិគំរាមកំហែង ឬ បង្ខិតបង្ខំទៅលើគ្នាទៅវិញទៅមក និងមិនអាចជំទាស់ពីភាគីម្ខាងទៀតបានឡើយ នៅពេលដែលគូភាគីបានរៀបអាពាហ៍ពិពាហ៍ថ្មី ។

២/ ស្តីអំពីការស្នើរសុំឲ្យចុងចម្លើយចុះចេញពីលំនៅដ្ឋាន

តាមការអះអាងរបស់ភាគីដើមចោទឈ្មោះ [redacted] ទូច បានស្នើរសុំឲ្យចុងចម្លើយចុះចេញពីលំនៅដ្ឋាន ហើយនៅនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ភាគីចុងចម្លើយក៏យល់ព្រមឯកភាព



Scanned with CamScanner

ចុះចេញចេញពីលំនៅដ្ឋានតាមការស្នើសុំ ម្យ៉ាងវិញទៀតគូភាគីពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍នឹងគ្នាតាមផ្លូវច្បាប់ឡើយ ដែលជាការរស់នៅជាមួយគ្នាបែបអនីតិសង្វាស ដូច្នេះគប្បីតុលាការពិចារណាតាមការព្រមព្រៀងរបស់គូភាគី ។

-នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ចុងចម្លើយឈ្មោះ [redacted] សំអឿន បានទាមទារប្រាក់ចំនួន ២៣ ម៉ឺនបាត ពីដើមចោទឈ្មោះ [redacted] ទូច និងស្នើសុំឲ្យដើមចោទលះបង់ការទាមទារលុយចំនួន ៧៥០០ $ ដោយដើមចោទក៏យល់ព្រមឯកភាពតាម ដូច្នេះគប្បីតុលាការពិចារណា និងសម្រេចតាមការព្រមព្រៀងរបស់គូភាគី ។

៣/ស្ដីអំពីប្រាក់ប្រដាប់ក្ដី

ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីចាញ់ក្ដី ។ តាមមាត្រា១០ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល និងមាត្រា៦៤ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## <u>សេចក្ដីសម្រេចបញ្ចប់</u>

១/ បញ្ជាក់ថាដើមចោទឈ្មោះ [redacted] ទូច ពិតជាពុំមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ជាមួយចុងចម្លើយឈ្មោះ [redacted] សំអឿន។

២/ បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] សំអឿន ចុះចេញពីផ្ទះ និងដី ដែលជាលំនៅដ្ឋានរបស់ដើមចោទឈ្មោះ [redacted] ទូច ។

៣/ បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] ទូច ប្រគល់ប្រាក់ចំនួន ២៣០០០០ (ម្ភៃបីម៉ឺន) បាត ឲ្យទៅចុងចម្លើយឈ្មោះ [redacted] សំអឿន និងទទួលស្គាល់ថាដើមចោទពិតជាបានលះបង់ការទាមទារប្រាក់ចំនួន ៧៥០០ (ប្រាំពីរប្រាំរយ) ដុល្លារអាមេរិក ពីចុងចម្លើយ ។

៤/ ប្រាក់ប្រដាប់ក្ដី គឺជាបន្ទុករបស់ចុងចម្លើយ ។

-សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការជាសាធារណៈ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ដោយចំពោះមុខដើមចោទឈ្មោះ [redacted] ទូច និងចុងចម្លើយឈ្មោះ [redacted] សំអឿន ។

-ភាគីដែលពុំសុខចិត្តនឹងសេចក្ដីសម្រេចបញ្ចប់នេះមានសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ០៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

បាត់ដំបង, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ** TM.

[redacted]



Scanned with CamScanner